# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 138

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : គម្រោងអភិវឌ្ឍន៍កៅស៊ូគ្រួសារនៅកម្ពុជា

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/23 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 01/01/30 |
| ៣. ចំណាយគម្រោងសរុប | $16,300,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| RESPONSIBLE UNIT | GDR |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានកៅស៊ូ |
| ៥. ស្ថានភាពគម្រោង | គម្រោងដែលបានលុបចោល |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងវិនិយោគជាទុន |
| ៧. ប្រភពហិរញ្ញប្បទាន៖ | ឥណទានសម្បទាន |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

បង្កើនប្រាក់ចំនូលដល់កសិករកៅស៊ូគ្រួសារ ដើម្បីចូលរួមការអភិវឌ្ឍន៍ជនបទ និងកាត់បន្ថយភាពក្រីក្រ

### ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

**១១. វិស័យ** (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី

Livestock

Research and Extension Services

Land Management

**១២. ទីតាំងអនុវត្តគម្រោង** (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

រតនគីរី, បាត់ដំបង,

**១៣. គោលបំណងរបស់គម្រោង** (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

-ធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅតាមទីតំបន់ជនបទតាមរយៈការបង្កើតការងារដល់គ្រួសារកសិករ
-បង្កើនប្រភពប្រាក់ចំណូលដែលបានមកពីការធ្វើអាជីវកម្មកៅស៊ូដល់កសិករនិងជួយកាត់បន្ថយភាពក្រីក្រ នៅតាមជនបទ
-បង្កើតប្រភពប្រាក់ចំណូលដល់រឿនសេដ្ឋកិច្ចជាតិតាមរយៈការនាំចេញផលិតផលកៅស៊ូ
-ការពារបរិស្ថានទល់នឹងភាពហួតហែងក្តៅខ្លាំងនៃធម្មជាតិនិងទប់ស្កាត់ការហូរច្រោះដី។

**១៤. ការពិពណ៌នាអំពីគម្រោង** (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

• សមាសភាគឥណទាន"មានគោលដៅផ្តល់ហិរញ្ញប្បទាន"សម្រាប់ការវិនិយោគទៅលើសម្ភារដាំដំណាំកៅស៊ូនានាដោយអ្នកដាំកៅស៊ូគ្រួសារតាមរយៈ សហគមន៍របស់ពួកគេ។
• សមាសភាគ"ជំនួយបច្ចេកទេសដល់អ្នកដាំកៅស៊ូគ្រួសា រនិងសហគមន៍របស់ពួកគេ"ដែលនឹង (១)រួមចំណែកក្នុងការឧបត្ថម្ភផ្នែកហិរញ្ញប្បទានបឋមសម្រាប់បង្កើតបណ្តាញជំនួយការបច្ចេកទេសដែល នឹងអាចជួយសម្រួលដល់អ្នកដាំកៅស៊ូគ្រួសារថ្មីៗ(នៅក្នុងស្រុកដែលបានជ្រើសរើសទាំង៧)និង (២)ផ្តល់ការប្រឹក្សាយោបល់ដល់សហគមន៍កសិករគ្រួសារទាំង១៥ដែលបានដាំដុះរួចនៅទូទាំងប្រទេស ដើម្បីពង្រឹងគុណភាពផលិតកម្មរបស់ពួកគេភ្ជាប់ជាមួយនឹងក្របខណ្ឌនៃកិច្ចព្រមព្រៀងកសិកម្មកិច្ចសន្យាជាមួយនឹងអ្នកកែច្នៃ/អ្នកនាំចេញ។
• សមាសភាគ "គាំពារទៅដល់សហគមន៍អ្នកដាំដំណាំកៅស៊ូ" ដែលនឹង (១) គាំទ្រការបង្កើតសហគមន៍អ្នកដាំកៅស៊ូគ្រួសារកម្រិតថ្នាក់ឃុំ និងស្រុកនៅក្នុងស្រុកគោលដៅទាំង៧សម្រាប់ការអភិវឌ្ឍកៅស៊ូគ្រួសារ និងជួយពង្រឹងសហគមន៍ទាំងនោះរហូតអាចក្លាយជាស្ថាប័នមួយដែលមាននិរន្តរភាពនៅពេលគម្រោងត្រូវបានបញ្ចប់ (២)គាំទ្រការបង្កើតសហគមន៍កៅស៊ូគ្រួសារថ្មីៗបន្ថែមទៀត ឬពង្រឹងសហគមន៍ចាស់ៗដែលមានស្រាប់។
• សមាសភាគ "ការគ្រប់គ្រងគម្រោង និងការគាំទ្រលើវិស័យដំណាំកៅស៊ូ" ដែលនឹងជួយគាំទ្រដល់ អង្គភាពគ្រប់គ្រង គម្រោង (PMU) គាំទ្រទៅដល់ប្រព័ន្ធត្រួតពិនិត្យវាយតម្លៃ គាំទ្រការទទួលស្គាល់គុណភាពច្បារពូជកៅស៊ូ សកម្មភាពស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា (CRRI) ការបង្កើតអនុការិយាល័យ ចំនួន២ដោយធនាគារអភិវឌ្ឍន៍ជនបទ(ធនាគារអភិវឌ្ឍន៍ជនបទ)ក្នុងខេត្តគោលដៅ និងផ្តល់ជំនួយបច្ចេកទេសដល់សាខាធនាគារអភិវឌ្ឍន៍ជនបទ និងមូលនិធិគាំទ្រសម្រាប់ការអភិវឌ្ឍកសិកម្មកៅស៊ូតាមកិច្ចសន្យា ដែលនឹងត្រូវយកទៅប្រើ ប្រាស់សម្រាប់ការវិនិយោគ ផ្នែកហិរញ្ញវត្ថុ និងសកម្មភាព ក្នុងគោលបំណងការធ្វើឱ្យប្រសើរឡើងផ្នែកទីផ្សារ និងគុណភាពកៅស៊ូនៅក្នុងសហគមន៍កសិករដាំកៅស៊ូគ្រួសារទាំង១៥ ដែលគាំទ្រដោយគម្រោង។ សមាសភាគនេះក៏នឹងគាំទ្រលើការអនុវត្តអនុសាសន៍នៃការសិក្សាលើវិស័យកៅស៊ូ និងលើផ្នែកទីផ្សារ/ការកែច្នៃកៅស៊ូនៅក្នុងប្រទេសកម្ពុជា។

**១៥. យុត្តិកម្មលើគម្រោង** (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

-កៅស៊ូជាផលិតផលកសិកម្មមួយក្នុងការអភិវឌ្ឍដែលស្ថិតនៅក្នុងមុំយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល
-ការអភិវឌ្ឍវិស័យកៅស៊ូលើកសិករកៅស៊ូគ្រួសារក្រីក្រ ដែលទាមទារការគាំទ្រការផ្តល់កម្ចីឥណទានរយៈ ពេលវែង និងការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដើម្បីឲ្យកសិករអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផលិត កៅស៊ូប្រកបគុណភាព និងចីរភាព

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

**កសិករកៅស៊ូគ្រួសារ មន្ត្រីបច្ចេកទេសនិងអ្នកស្រាវជ្រាវ នឹងទទួលបានផលដោយផ្ទាល់ពីគម្រោងនេះ**

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **ត្រូវបានបញ្ចប់**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះមិនមានផលប៉ះពាល់ដល់ប្រជាជន និងបរិស្ថានដែលនៅជុំវិញទេ**
**ហើយគម្រោងនេះអាចជួយកាត់បន្ថយភាពក្រីក្រដល់កសិករកៅស៊ូគ្រួសារ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|
| **១៣. ជីវភាពរស់នៅ (ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ)** | 83 | **ទាក់ទងខ្លាំង** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**ចំពោះការអនុវត្តគម្រោងនេះមិនមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីទេ**
**ទាំងបុរសនិងស្ត្រីអាចចូលរួមអនុវត្តក្នុងគម្រោងនេះបានដូចគ្នា។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**អគ្គនាយកដ្ឋានកៅស៊ូមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោង**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**គម្រោងអាចត្រូវបានពន្យាពេលដោយមូលហេតុថា**
**-មិនទាន់បានបញ្ចប់ការធ្វើការសិក្សាលទ្ធភាពអាចធ្វើបានក្នុងដំណាក់កាលទីពីរ**
**-រដ្ឋាភិបាលមិនទាន់សម្រេចទទួលយកគម្រោងនេះនៅឡើយ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**កំពុងស្វែងរក**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2022 | | 2023 | 2024 | 2025 | 2026 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2024-2026 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 230.8 | 308.1 | 441.1 | 980.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 37.0 | 37.0 | 37.0 | 111.0 | 0.0 |
| សម្ភារ:និងរដ្ឋបាល | 0.0 | 0.0 | 0.0 | 193.8 | 271.1 | 271.1 | 736.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 133.0 | 133.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 2,759.9 | 5,258.9 | 7,301.2 | 15,320.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 2,000.0 | 4,915.6 | 6,926.5 | 13,842.1 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 338.3 | 63.1 | 39.1 | 440.5 | 0.0 |
| ទព្វសម្ភារ: | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 392.7 | 234.6 | 259.6 | 886.9 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 28.9 | 45.6 | 76.0 | 150.5 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 2,990.7 | 5,567.0 | 7,742.3 | 16,300.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2022 | | 2023 | 2024 | 2025 | 2026 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2024-2026 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 2,990.7 | 5,567.0 | 7,742.3 | 16,300.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: